ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៩៦
ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩
សាលដីកា
លេខ ២៨ "ព"
ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

## សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៧៥ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃលេង ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៣ ក្រអ "វ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលមាន ៖

-បុគ្គលប្តឹងសាទុក្ខ៖ ជនជាប់ចោទឈ្មោះ [redacted] ផៃលេង ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

- មានលោក [redacted] ផានិត ជាមេធាវីការពារ។



Scanned with CamScanner

-ជាប់ចោទពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិកែង ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧, ២៣៩, ២៤០ ចំណុច ៥ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីឡូត ភេទស្រី អាយុ ១៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តក្រចេះ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ២៣ និង ២០នាទី ឈ្មោះ [redacted] សោម ភេទប្រុស, ឈ្មោះ [redacted] ផៃលេង ភេទប្រុស, ឈ្មោះ [redacted] កញ្ញារី ហៅ [redacted] ប៉ាញ់ ភេទប្រុស និងឈ្មោះ [redacted] ពន្រ្ទា ហៅ [redacted] ចន្រ្ទា ភេទប្រុស បាននាំគ្នាអង្គុយផឹកស៊ីនៅលើគ្រែក្បែរផ្លូវ ហើយក៏បានឃើញឈ្មោះ [redacted] ស្រីឡូត ភេទស្រី ដើរម្នាក់ឯង ឈ្មោះ [redacted] សោម ក៏បានស្រែកហៅនាងឱ្យចូលទៅកាន់កន្លែងដែលពួកខ្លួនផឹកស៊ី នៅពេលដែលឈ្មោះ [redacted] ស្រីឡូត ដើរចូលទៅដល់ស្រាប់តែឈ្មោះ [redacted] ផៃលេង បានចាប់ទាញនាងឡើងលើគ្រែហើយបានអោបថើប តែត្រូវបានឈ្មោះ [redacted] ស្រីឡូត របើម្រាស់រួចហើយឈ្មោះ [redacted] ផៃលេង ចាប់អូសនាងទៅមាត់ស្រះ ហើយបានចាប់ស្រាតខោ អោបថើបនាងបម្រុងរំលោភសេពសន្ថវៈ តែមិនបានសម្រេចដោយឈ្មោះ [redacted] ស្រីឡូត រើរួចស្លៀកខោ រត់មកកន្លែងពេងផឹកស៊ី ដើម្បីឱ្យគេជួយ ប៉ុន្តែត្រូវបានឈ្មោះ [redacted] សោម ខ្ទប់មាត់កុំឱ្យនាងស្រែក ហើយឱ្យឈ្មោះ [redacted] ផៃលេង ចាប់ស្រាតខោ ប្រេបាច់ដោះព្រមទាំងបានយកដៃលូកចូលប្រដាប់ភេទរបស់ឈ្មោះ [redacted] ស្រីឡូត ហើយឈ្មោះ [redacted] កញ្ញារី ហៅ [redacted] ប៉ាញ់ និងឈ្មោះ [redacted] ន្រ្ទា ហៅ [redacted] ចន្រ្ទា ជាអ្នកមើលផ្លូវ តែត្រូវបានឈ្មោះ [redacted] យ៉ាត ជាម្តាយមីងរបស់ជនរងគ្រោះមកទាន់ ហើយឈ្មោះ [redacted] ផៃលេង, ឈ្មោះ [redacted] សោម, ឈ្មោះ [redacted] កញ្ញារី ហៅ [redacted] ប៉ាញ់ និងឈ្មោះ [redacted] ពន្រ្ទា ហៅ [redacted] ចន្រ្ទា ឃើញក៏នាំគ្នារត់គេចខ្លួនបាត់ ។

សាលាដំបូងខេត្តក្រចេះ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ២៧ (គ) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅនេះ ៖

១-ផ្តន្ទាទោសជនជាប់ចោទ៖

ក-ឈ្មោះ [redacted] ផៃលេង ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ គិតពីថ្ងៃឃុំខ្លួនពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោស) ប្រព្រឹត្តនៅចំណុចភូមិកែង ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧, ២៣៩, ២៤០ ចំណុច ៥ នៃក្រមព្រហ្មទណ្ឌ ។

ខ-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ប៉ាញ់ ហៅ [redacted] កញ្ញារី ភេទប្រុស

គ-ឈ្មោះ [redacted] ពន្រ្ទា ហៅ [redacted] ចន្រ្ទា ភេទប្រុស

Scanned with CamScanner

ឃ-និងឈ្មោះ [redacted] សោម ភេទប្រុស ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ០៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោស) ប្រព្រឹត្តនៅចំណុចភូមិកែង ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧, ២៣៩, ២៤០ ចំណុច ៥ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ប៉ាញ់ ហៅ [redacted] កញ្ញារី ភេទប្រុស, ឈ្មោះ [redacted] សោម ភេទប្រុស, ឈ្មោះ [redacted]ពន្រ្ទា ហៅ [redacted]ចន្ទ្រា ភេទប្រុស ។

៣-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផៃលេង កំបាំងមុខជនជាប់ចោទ ឈ្មោះ [redacted] កញ្ញារី ហៅ [redacted]ប៉ាញ់ ភេទប្រុស និងឈ្មោះ [redacted]ពន្រ្ទា ហៅ [redacted]ចន្ទ្រា ភេទប្រុស។

-បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមច្បាប់ ។

សាលក្រមនេះត្រូវបានជនជាប់ចោទឈ្មោះ [redacted] ផៃលេង ប្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ៣៣ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ គ្រង់ចំណុចទាំងមូលនៃសាលក្រម។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ២៣ ក្រII "វ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃលេង ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូង ខេត្តក្រចេះ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ។

-បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

សាលដីកានេះ ត្រូវបានជនជាប់ចោទឈ្មោះ [redacted] ផៃលេង ប្តឹងសាទុក្ខ តាមបណ្តឹងលេខ ៧៥ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលនៃសាលដីកា។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា តាមអង្គហេតុ ដោយផ្អែក លើចម្លើយសារភាពរបស់ជនជាប់ចោទនៅចំពោះមន្ត្រីនគរបាលយុត្តិធម៌ នៅចំពោះមុខតំណាង និង



Scanned with CamScanner

ទៅក្រុមស៊ើបសួរ ព្រមទាំងចម្លើយរបស់ជនរងគ្រោះ ដើមបណ្ដឹងមានភាពស៊ីចង្វាក់ ដែលអាចបញ្ជាក់ថា ជនជាប់ចោទ [redacted] ផៃលេង, [redacted] សោម, [redacted] កញ្ញារី និងឈ្មោះ [redacted] ពន្ធា ពិតជាបានប្រព្រឹត្ត អំពើប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់) ប្រព្រឹត្តនៅភូមិកែង ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២៧ មាត្រា ២៣៩ និង ២៤០ ចំនុច ៥ នៃក្រមព្រហ្មទណ្ឌប្រាកដមែន។ យល់ឃើញថា នៅក្នុងសារណាបញ្ជាក់ពីមូលហេតុសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] ផៃលេង បានបដិសេធថា ខ្លួនពុំបានប្រព្រឹត្តអំពើប៉ុនប៉ងរំលោភ លើជនរងគ្រោះនោះទេ ចម្លើយសារភាពកន្លងមកគឺជាការរៀបចំរបស់ប៉ូលីស ដែលបង្ខំឱ្យខ្លួនឆ្លើយ។ ព្រមជាមួយនេះ នៅក្នុងសារណារបស់ដើមបណ្ដឹងឈ្មោះ [redacted] យ៉ាត និងសារណារបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីឡូត បានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា ឈ្មោះ [redacted] ផៃលេង ពុំបានប៉ុនប៉ងចាប់រំលោភជនរងគ្រោះនោះទេ សុំឱ្យតុលាការលើកលែងចោទប្រកាន់លើ ឈ្មោះ [redacted] ផៃលេង និងគូកន ខ្លួនបានដកពាក្យបណ្ដឹងឈប់ប្ដឹងហើយ។ សារណារបស់ជនរងគ្រោះ និងដើមបណ្ដឹង បានលើកមូលហេតុដើម្បីដោះបន្ទុកឱ្យជនជាប់ចោទ ដោយលើកមូលហេតុមួយចំនួនដែលមិនគួរឱ្យជឿបាន ព្រមទាំងធ្វើឱ្យមានភាពមន្ទិលសង្ស័យទៅលើពិរុទ្ធភាព ដែលដាក់បន្ទុកទៅលើជនជាប់ចោទ។ ហេតុដូច្នេះតំណាងមហាអយ្យការសូមទុកជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] ផៃលេង បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ពីដំបូងឡើងខ្លួនអង្គុយផឹកស្រាលេង មានគ្នា ៤នាក់ នៅកែងមាត់ផ្លូវ ហើយឈ្មោះ ស្រីឡូត បានដើរមកលេងជាមួយខ្លួន និងតាមដណ្ដើមទូរស័ព្ទខ្លួន ដើម្បីទៅមើលចម្រៀង ពេលនោះឈ្មោះ [redacted] យ៉ាត បានដើរមកឃើញ ហើយក៏ប្ដឹងខ្លួនតែម្ដងទៅ។

-លោកមេធាវី [redacted] ផានិត បានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានសិក្សាសំណុំរឿង ក្រោយពីបានស្ដាប់ការសួរដេញដោលរបស់ក្រុមប្រឹក្សាជំនុំជម្រះ និងសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ខ្លួនយល់ឃើញថា រឿងនេះគឺពិតជាអត់មានអំពើរំលោភកើតឡើងទេ។ បើយើងពិនិត្យមើលទៅអង្គហេតុ និងទីតាំងគឺពិតជាមិនអាចនឹងមានរឿងរំលោភកើតឡើងនោះទេ។ អង្គហេតុគឺកើតឡើងពីឈ្មោះ [redacted] ស្រីឡូត ទៅកន្លែងទីតាំងកើតហេតុមុន ហើយវាស៊ីចង្វាក់គ្នា ទាក់ទងទៅនឹងការប្រលែងគ្នាដណ្ដើមទូរស័ព្ទ ពីជនជាប់ចោទឈ្មោះ [redacted] ផៃលេង ពេលនោះហើយដែលធ្វើឱ្យម្ដាយមីងឈ្មោះ [redacted] យ៉ាត មកឃើញធ្វើឱ្យមានការខឹងសម្បា គាត់ក៏បានទៅប្ដឹងសមត្ថកិច្ចប៉ុស្តិ៍ ដើម្បីឱ្យទៅប្រដៅក្រុមយុវជនទាំងនោះ ប៉ុន្តែសមត្ថកិច្ចបែរជាបង្កសំណុំរឿងនេះទៅជាសំណុំរឿងព្រហ្មទណ្ឌទៅវិញ។ ទាក់ទងទៅនឹងភស្តុតាងគឺគ្មានភស្តុតាងអ្វីក្រៅពីសម្ដីសោះ អ៊ីចឹងពាក្យសម្ដីពេលប្ដឹងនិយាយដាក់បន្ទុកពេលបាត់ខឹងនិយាយដោះបន្ទុក។ សមត្ថកិច្ចកសាងសំណុំរឿងគឺយកតាមតែសម្ដីម្ខាង ដែលមិនបានស្វែងរកភស្តុតាងអ្វីផ្សេងនោះទេ។ ខ្លួនសុំឱ្យក្រុមប្រឹក្សាមេត្តា ពិចារណា ទៅលើរឿងទាំងអស់នេះខ្លួនយល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ២៨ ក្រII



Scanned with CamScanner

"រ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ គឺមិនត្រឹមត្រូវ ព្រោះថាខ្វះធាតុផ្សំ ខ្វះភស្តុតាង ស៊ីចង្វាក់ទៅនឹងបទល្មើស។ ដូច្នេះខ្លួនសុំឱ្យក្រុមប្រឹក្សាមេត្តា ពិចារណាឱ្យជនជាប់ចោទរួចផុតពីបទចោទ។

-ក្រឡាបញ្ជី បានអានសារណាតបរបស់ឈ្មោះ [redacted] យ៉ាត និងឈ្មោះ [redacted] ស្រីឡូត។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារ
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧៥ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ឆៃលេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨ និង មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២. យល់ឃើញថា នៅក្នុងរឿងក្តីនេះពាក់ព័ន្ធនឹងជនជាប់ចោទចំនួន ៤ នាក់ ប៉ុន្តែមានតែជនជាប់ចោទឈ្មោះ [redacted] ឆៃលេង ម្នាក់ប៉ុណ្ណោះដែលបានប្តឹងសាទុក្ខ ។ ហេតុនេះ តុលាការកំពូលធ្វើការវិនិច្ឆ័យសេចក្តីតែក្នុងក្របខណ្ឌនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទដែលបានប្តឹងសាទុក្ខប៉ុណ្ណោះ ។

៣. យល់ឃើញថា តុលាការអង្គហេតុសម្រេចថា ជនជាប់ចោទឈ្មោះ [redacted] ឆៃលេង មានពិរុទ្ធភាពពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ដោយសំអាងទៅលើចម្លើយរបស់ជនជាប់ចោទ និងជនរងគ្រោះដែលបានឆ្លើយមុនពេលសវនាការនៅសាលាដំបូងខេត្តក្រចេះ ដែលថា នារីរងគ្រោះបានដើររកអ៊ំស្រីរបស់នាង ហើយក៏បានជួបនឹងជនជាប់ចោទចំនួន ៤ នាក់ ដែលកំពុងផឹកស៊ីនៅលើគ្រែមុខផ្ទះឈ្មោះ ជឿន ហើយឈ្មោះ ពន្លា ក៏បានហៅនាងឱ្យចូលសិន និងបន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] ឆៃលេង បានចាប់ដៃនាងទាញទៅកន្លែងមាត់ស្រះទឹក បានចាប់ស្រាតខោនាងហូតផុតពីជើងម្ខាង តែនាងរបើច រួចក៏ស្លៀកខោរត់មកកន្លែងគ្រែផឹកស៊ីវិញ ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] ឆៃលេង ក៏រត់តាមចាប់ស្រាតខោនាងម្តងទៀត ខណៈពេលនោះឈ្មោះ [redacted] យ៉ាត ក៏បានដើរមកដល់ ហើយក្រុមជនជាប់ចោទក៏នាំគ្នារត់ចេញពីកន្លែងកើតហេតុនោះទៅ ។

ចំពោះករណីនេះ តុលាការកំពូលពិនិត្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ឆៃលេង ក៏ដូចជាជនរងគ្រោះ ឈ្មោះ [redacted] ស្រីឡូត បានឆ្លើយបំភ្លឺនាពេលសវនាការនៅសាលាដំបូងខេត្តក្រចេះថា នៅពេលដែលជនរងគ្រោះដើរចូលមកកន្លែងដែលក្រុមជនជាប់ចោទកំពុងផឹកស៊ី នារីរងគ្រោះក៏បានយកទូរស័ព្ទរបស់ជនជាប់ចោទឈ្មោះ [redacted] ឆៃលេង មកលេង តែជនជាប់ចោទឈ្មោះ [redacted] ឆៃលេង មិនព្រមឱ្យ ទើបកើតមានការប្រេតាយ



Scanned with CamScanner

ឆ្នាបណ្តាលឱ្យ នារីរងគ្រោះដួលលើគ្រែ ហើយជនជាប់ចោទឈ្មោះ [redacted] ធៃលេង ក៏ទ្រោបពីលើនាង ហើយម្តាយមីងរបស់នារី រងគ្រោះបានមកដល់ ក៏មានរឿងរ៉ាវប្តឹងផ្តល់កើតឡើង។ ដូច្នេះមានភាពខុសប្លែកគ្នារវាងចម្លើយរបស់ជនជាប់ចោទនិងចម្លើយជនរងគ្រោះនៅមុនពេលសវនាការ និងនៅក្នុងពេលសវនាការនៅសាលាដំបូង ដែលនាំឱ្យមានវិមតិសង្ស័យលើពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ធៃលេង ។ ជាពិសេសនៅក្នុងរឿងហេតុនេះពុំមានភស្តុតាងបញ្ជាក់ពីការស្រែកឱ្យគេជួយរបស់នារីរងគ្រោះឡើយ ពីព្រោះថា អង្គហេតុបានកើតឡើងនៅ លើគ្រែ ស្ថិតនៅមុខផ្ទះរបស់អ្នកភូមិ ប្រសិនបើនារីរងគ្រោះស្រែកឱ្យគេជួយ នោះប្រាកដជាមានការផ្អើលតោឡោជាក់ជាមិនខាន ។

នៅក្នុងសារណាតបរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីឡូត ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ នាង បានសរសេររៀបរាប់ដោយបដិសេធនូវចម្លើយរបស់ខ្លួនដែលបានឆ្លើយបំភ្លឺនៅនគរបាលថា "ឈ្មោះ [redacted] ធៃលេង , [redacted] សោម និងឈ្មោះ [redacted] កញ្ញារី បានលូកស្ទាបប្រដាប់ភេទខ្លួននោះ ថាជាចម្លើយមិនពិត គឺជា ចម្លើយដែលគេបញ្ចេះឱ្យនាងឆ្លើយអ៊ីចឹងទេ ។ ការពិត នៅយប់កើតហេតុនោះឈ្មោះ [redacted] ធៃលេង និងនាង បានប្រឡែងគ្នា ដោយខ្លួនបានកញ្ឆក់យកទូរស័ព្ទពីដៃរបស់ [redacted] ធៃលេង យកមកមើលបទចម្រៀង តែឈ្មោះ [redacted] ធៃលេង បានដេញចាប់ខ្លួន ដោយបានចាប់ដៃ និងចាប់ទាញសក់នាងដណ្តើមយកទូរស័ព្ទគាត់ទៅវិញ ជួនចំពេលដែលអ៊ុ(មីង) របស់នាងឈ្មោះ [redacted] យ៉ាត ដើរមកឃើញ ក៏បានធ្វើឱ្យគាត់មានការភ័ន្តច្រឡំ ដោយ ស្មានថាឈ្មោះ [redacted] ធៃលេង ចាប់នាងប៉ុនប៉ងរំលោភ ទើបគាត់រាយការណ៍ជូនទៅសមត្ថកិច្ចតែម្តងទៅ។ តែ ការពិតនោះ ឈ្មោះ [redacted] ធៃលេង មិនបានប៉ុនប៉ងចាប់រំលោភលើនាងនោះទេ និងសុំបដិសេធសាលក្រម ព្រហ្មទណ្ឌលេខ ២៧ (គ) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តក្រចេះ និងសាលដីកា លេខ ២៣ ក្រ.II "រ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ និងប្តឹងសុំ តុលាការកំពូលសម្រេចលើកលែងចោទប្រកាន់លើឈ្មោះ [redacted] ធៃលេង , [redacted] កញ្ញារី , [redacted] សោម និងឈ្មោះ [redacted] ពន្រ្ទា ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសនោះវិញ ។

នៅក្នុងសារណាតបរបស់ឈ្មោះ [redacted] យ៉ាត ជាម្តាយមីងរបស់ឈ្មោះ [redacted] ស្រីឡូត ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ នាងបានសរសេររៀបរាប់ពីរឿងហេតុដែលកើតមានប្រហាក់ប្រហែលនឹងឈ្មោះ [redacted] ស្រីឡូត ដែរ និងបញ្ជាក់ថាខ្លួនបានផ្តល់ចម្លើយនៅចំពោះមុខតុលាការខេត្តក្រចេះថា "នាងមើលតាមពន្លឺភ្លើងពិលអ៊ីរ (ជិតអស់ថាមពល) មើលមិនច្បាស់នៅទេ ពីព្រោះជាពេលយប់ងងឹត និងនាងសុំបដិសេធនូវចម្លើយដែលខ្លួនបានឆ្លើយកន្លងមកទាំងអស់ ទាំងនៅប៉ូលិស និងនៅចៅក្រមស៊ើបសួរ" ដោយហេតុថា វាមិនមែនជារឿងផ្ទាល់ខ្លួនរបស់នាងទេ ។ ម្យ៉ាងទៀត ចម្លើយសាមីខ្លួនឈ្មោះ [redacted] ស្រីឡូត បានឆ្លើយថាពុំមានអ្នកណាចាប់នាងប៉ុនប៉ងរំលោភនោះទេ និងសំណូមពរសុំបដិសេធសាលក្រមព្រហ្មទណ្ឌលេខ ២៧(គ) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តក្រចេះ និងសាលដីកា លេខ ២៣ ក្រ.II "រ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់និងប្តឹងសុំតុលាការកំពូលសម្រេចលើកលែងចោទប្រកាន់ លើ



Scanned with CamScanner

ឈ្មោះ [redacted] ឆៃលេង , [redacted] កញ្ញារី , [redacted] សោម និងឈ្មោះ [redacted] ពុទ្ធា ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសនោះវិញ ។

ហេតុផលទាំងប៉ុន្មានដែលបានលើកបង្ហាញដូចខាងលើនេះ នាំឱ្យមានវិមតិសង្ស័យលើជនជាប់ចោទពីបទល្មើសដែលបានចោទប្រកាន់ដូចមានបញ្ញត្តមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិមាត្រា ៣៥១ ត្រង់កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ *"វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច"។*

ហេតុដូច្នេះ ដោយអនុវត្តតាមបទប្បញ្ញត្តិមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលសម្រេចបដិសេធសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តក្រចេះ ដែលពាក់ព័ន្ធនេះ ដោយមិនចាំបាច់បង្វិលសំណុំរឿងត្រឡប់ទៅសាលាឧទ្ធរណ៍ភ្នំពេញវិញឡើយ ។

៤. យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទមានមូលហេតុត្រឹមត្រូវតាមបទប្បញ្ញត្តិមាត្រា ៤១៩ ត្រង់ចំណុចទី៧ *"ការបំភ្លៃអង្គហេតុ"* នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥. យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា តាមអង្គហេតុផ្អែកតាមចម្លើយរបស់ជនជាប់ចោទនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចំពោះមុខអយ្យការ និងចៅក្រមស៊ើបសួរ ព្រមទាំងចម្លើយជនរងគ្រោះ ដើមបណ្តឹង ឃើញថា មានភាពស៊ីចង្វាក់គ្នាបញ្ជាក់ថា ជនជាប់ចោទនិងគូកនពិតជាបានប្រព្រឹត្តបទល្មើសប៉ុនប៉ងរំលោភសេពសន្ថវៈដូចការចោទប្រកាន់ ។ ចំណែកឯ សារណាបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ [redacted] ឆៃលេង បដិសេធថា ខ្លួនមិនបានប្រព្រឹត្តអំពើប៉ុនប៉ងរំលោភសេពសន្ថវៈដូចការចោទប្រកាន់ និងបង្ហាញពីភាពមិនមានជំនឿលើខ្លឹមសារនៃសារណាតបរបស់ដើមបណ្តឹងឈ្មោះ [redacted] យ៉ាត និងសារណាជនរងគ្រោះឈ្មោះ [redacted] ស្រីឡូត ប៉ុន្តែបានបង្ហាញពីភាពមានមន្ទិលសង្ស័យពីពិរុទ្ធភាពដែលដាក់បន្ទុកលើជនជាប់ចោទដែរ និងសុំឱ្យក្រុមប្រឹក្សាពិចារណា សម្រេចតាមច្បាប់។ សេចក្តីសន្និដ្ឋានដូចនេះក៏ការនេះបញ្ជាក់ឱ្យឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការមួយផ្នែកក៏សមស្របទៅនឹងខ្លឹមសារផ្នែកសំអាងហេតុដូចខាងលើរបស់អង្គជំនុំជម្រះដែរ ។

៥. យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៣ ក្រ "វ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ២៧ (គ) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តក្រចេះ ចំពោះតែផ្នែកដែលពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ឆៃលេង ដែលបានសម្រេចមក នេះ មិនត្រឹមត្រូវតាមច្បាប់ឡើយ ។

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១. ទទួលបណ្តឹងសាទុក្ខលេខ ៧៥ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ឆៃលេង ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។



Scanned with CamScanner

២. បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ២៣ ក្រ II "ក" ចុះថ្ងៃទី១៣ ខែមីនាឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ និងសាលក្រមព្រហ្មទណ្ឌលេខ ២៧ (គ) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តក្រចេះ ចំពោះតែផ្នែកដែលពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ផៃលេង ។

៣. ឱ្យឈ្មោះ [redacted] ផៃលេង រួចខ្លួន រួចផុតពីការចោទប្រកាន់ បទប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិកែង ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ។

៤. បង្គាប់ឱ្យដោះលែងឈ្មោះ [redacted] ផៃលេង ឱ្យមានសេរីភាពជាបន្ទាន់ ប្រសិនបើបុគ្គលឈ្មោះ [redacted] ផៃលេង នេះមិនត្រូវបានជាប់ឃុំខ្លួនពីបទល្មើសណាផ្សេងទៀតទេ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី៣១ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ។

Scanned with CamScanner